# គណបក្ស សិទ្ធិមនុស្ស
# HUMAN RIGHTS PARTY

បំរើ ការពារ កសាង

## កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍ ថ្ងៃសុក្រ ទី១៣ ខែមីនា ឆ្នាំ២០០៩ ព្រឹត្តិប័ត្រលេខ០៧៦ ឆ្នាំទី២*



| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ចុះជួបសំណេះសំណាលជាមួយ សកម្មជននៅខេត្តកំពត | ១ |
| -សភាកោះប្រជុំវិសាមញ្ញផ្តល់សេចក្តីទុកចិត្តដល់ឧបនាយករដ្ឋមន្ត្រីទី១០ | ២ |
| -ប្រជាពលរដ្ឋនៅខេត្តក្រចេះកំពុងព្រួយបារម្ភពីបញ្ហាការរំលោភដីធ្លី | ៣ |
| -ការឃើញយ៉ាងបើកប្រាក់បន្ថែម ៥ដុល្លារដល់មន្ត្រីប៉ូលីសតែប្រសើរជាងអត់ | ៤ |


## ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះជួបសំណេះសំណាលជាមួយសកម្មជននៅខេត្តកំពត

ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស បានជួបសំណេះសំណាល សួរសុខទុក្ខ និងថ្លែងសារនយោបាយទៅកាន់ប្រជាពលរដ្ឋ និងសកម្មជនគណបក្សសិទ្ធិមនុស្ស នៅភូមិត្រពាំងល្បើក ឃុំត្រពាំងបី ស្រុកឈូក ខេត្តកំពត កាលពីរសៀលថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៩។

លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យរបស់គណបក្សសិទ្ធិមនុស្ស មានប្រសាសន៍ទៅកាន់ប្រជាពលរដ្ឋ ថាក្រោយការបោះឆ្នោត ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ គណបក្សប្រជាជនទទួលបាន៩០អាសនៈ ហើយគួរណាស់តែគណបក្សកាន់អំណាច ពង្រីកយកឥទ្ធិពលដោយនាំជនក្រីក្រកម្ពុជាទាំងឡាយឆ្ពោះទៅត្រើយនៃសេចក្តីប្រាថ្នា កុំឱ្យអភ័ព្វដូចសព្វថ្ងៃទៀត។

លោក **ប៉ែន សុវណ្ណ** បន្តថា គណបក្សកាន់អំណាចសព្វថ្ងៃធ្វើឱ្យខ្មែរក្រីក្រ ហើយលោកក៏បានរំឭកដល់ អតីតកាលជំនាន់លោកធ្វើជា នាយករដ្ឋមន្ត្រីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាកំឡុងឆ្នាំ១៩៨០ នោះបានបញ្ជាក់ថា ប្រជាពលរដ្ឋស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក គឺលោកមិនបោះបង់ចោលឱ្យប្រជាពលរដ្ឋរស់នៅក្រីក្ររហេមរហាមនោះទេ ។ ជំនាន់លោកធ្វើជានាយករដ្ឋមន្ត្រីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាកំឡុងឆ្នាំ១៩៨០ នោះបានបញ្ជាក់ថា ប្រជាពលរដ្ឋស្ថិតក្រោមការគ្រប់គ្រងរបស់លោក គឺលោកមិនបោះបង់ចោលឱ្យប្រជាពលរដ្ឋរស់នៅក្រីក្ររហេមរហាមនោះទេ ។ សព្វថ្ងៃនេះប្រទេសខ្មែរជាប្រទេសអត់ច្បាប់ ច្បាប់នៅមាត់ មាត់អនុវត្តច្បាប់ព្រៃទាំងអ្នកតូច អ្នកធំមួយចំនួនរំលោភច្បាប់ ។ លោកក៏បានអំពាវនាវឱ្យខ្មែរគ្រប់គណបក្សនយោបាយសាមគ្គីដើម្បីឱ្យជនក្រីក្រជាម្ចាស់ទឹក ដី និងមានច្បាប់សំរាប់ការពារ ។

លោក **កឹម សុខា** សមាជិករដ្ឋសភា របស់គណបក្សសិទ្ធិមនុស្ស និងជាប្រធានគណបក្សផងនោះបានថ្លែងថា បញ្ហា

សង្គមកិច្ចមានសភាពធ្ងន់ធ្ងរណាស់ ពីព្រោះគណបក្សកាន់អំណាចគ្មានវិធានការច្បាស់លាស់នោះទេហើយ លោក **កឹម សុខា** ក៏បានលើកយកចំណុចនេះមកនិយាយជាច្រើនលើកហើយដែរប៉ុន្តែយើងធ្វើមិនបាន ចំណែកប្រទេសដទៃគេធ្វើបានអំពីបញ្ហាសង្គមកិច្ចនេះ ។ រដ្ឋាភិបាលណាក៏ដោយក៏គេជួយមនុស្សចាស់ដែលអត់ធ្វើការកើតចាប់ពីអាយុ ៦៥ឆ្នាំ ឡើងទៅ ។

លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស មានប្រសាសន៍ទៀតថា សព្វថ្ងៃនេះបញ្ហាសង្គមនយោបាយ សេដ្ឋកិច្ចគឺមានស្ថានភាពធ្ងន់ធ្ងរណាស់ ហើយប្រជាពលរដ្ឋមួយចំនួនដែលមើលឃើញថា ធ្វើផ្លូវកសាងសាលារៀន មន្ទីរពេទ្យនេះពុំមែនជាលុយរបស់គណបក្សប្រជាជននោះទេ ។ តាមពិត គឺជាថវិកាជំនួយពីសហគមន៍អន្តរជាតិដោយសារតែ សិទ្ធិសញ្ញា២៣ ខែតុលា ឆ្នាំ ១៩៩៣ ដែលមានប្រទេស១៨ ជាម្ចាស់ហត្ថលេខី គឺពុំមែន ៧ មករា ឆ្នាំ១៩៧៩ នោះទេ ហើយ៧មករាក៏គ្មានប្រទេសណាគេជួយដែរ ដោយសារតែយួនចូលស្រុកខ្មែរហើយអង្គការសហប្រជាជាតិក៏មិនទទួលស្គាល់រដ្ឋាភិបាលនោះផងដែរពោលគឺ គេចាប់ជួយខ្មែរក្រោយពីកិច្ចព្រមព្រៀងក្រុងប៉ារីស ។

## សភាគោះប្រជុំវិសាមញ្ញផ្តល់សេចក្តីទុកចិត្តដល់ឧបនាយករដ្ឋមន្ត្រីទី១០

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ រដ្ឋសភានឹងបើកសម័យប្រជុំវិសាមញ្ញរបស់ខ្លួន ដើម្បីបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំងសមាជិករដ្ឋាភិបាលចំនួន១០រូប បន្ថែមលើសមាជិករដ្ឋាភិបាលដែលមានស្រាប់ ហើយការផ្តល់សេចក្តីទុកចិត្តរបស់រដ្ឋសភាចំពោះឧបនាយករដ្ឋមន្ត្រីទី១០របស់សមាជិករដ្ឋាភិបាល ។

លោក **រ៉ុង ឈុន** ប្រធានសមាគមគ្រូបង្រៀនឯករាជ្យបានបញ្ជាក់ថា ការបំប៉ោងសមាជិកគណៈរដ្ឋមន្ត្រីធ្វើអោយមានអភិបាលកិច្ចអាក្រក់ និងចំណាយថវិកាជាតិច្រើនអត់ប្រយោជន៍។ ស្ថិតក្នុងកាលៈទេសៈបច្ចុប្បន្ន ដែលពិភពលោកកំពុងជួបវិបត្តិហិរញ្ញវត្ថុរដ្ឋាភិបាលកម្ពុជា គួរណាស់តែពិចារណាសន្សំថវិការជាតិដើម្បីទប់ទល់នឹងវិបត្តិនៃការបាត់បង់ការងារកម្មករ។

លោក **ផៃ ស៊ីផាន** អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីមានប្រសាសន៍ថា ការតែងតាំងសមាជិករដ្ឋាភិបាលបន្ថែមដើម្បីត្រូវការមនុស្សច្រើនផ្តល់សេវាកម្មឱ្យបានប្រសើរនេះ គឺជារបស់នយោបាយក្នុងកិច្ចកែទំរង់រដ្ឋបាល របស់រាជាណាចក្រកម្ពុជាដោយប្រមុខរដ្ឋាភិបាលចង់ផ្តល់សេវាកម្មឱ្យបានប្រសើរដល់ប្រជាពលរដ្ឋ។

លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យរបស់គណបក្សសិទ្ធិមនុស្ស មានប្រសាសន៍ផ្ទុយពីប្រសាសន៍លើកឡើងរបស់លោក **ផៃ ស៊ីផាន** ទៅវិញដោយលោកបញ្ជាក់ថា អាណត្តិទី៤នេះមានការបោះឆ្នោតជាកញ្ចប់ ដែលការបោះឆ្នោតនេះមិនតាមឆន្ទៈប្រជាពលរដ្ឋ ហើយប្រទេសកម្ពុជាយើងតូច ដែលជាបច្ច័យអាក្រក់ដល់ប្រទេសជាតិយើង ។

សូមជំរាបថា សមាសភាពសមាជិករដ្ឋាភិបាលមានប្រមាណជាង៤០០រូប ក្នុងនោះមានរដ្ឋលេខាធិការដល់ នាយករដ្ឋមន្ត្រីមានប្រមាណ២៦៥រូប រដ្ឋាភិបាលបានតែងតាំងសមាជិករដ្ឋាភិបាល១០រូបបន្ថែមទៀតក្នុងនោះមាន ហើយបច្ចុប្បន្នមានឧបនាយករដ្ឋមន្ត្រី១០រូប សំរាប់សមាជិករដ្ឋាភិបាលអាណត្តិទី ៤ មានចំនួនច្រើនសន្ធឹកសន្ធាប់យ៉ាងច្រើន ដូច្នេះត្រូវបានគេថារដ្ឋាភិបាលមានមើលឃើញក្បាលធំជាងខ្លួន ដែលនោះជាការចាយវាយថវិកាជាតិខ្ជះខ្ជាយនោះពេលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ និងមន្ត្រីរាជការមានប្រាក់ខែតិចតួចផងនោះ ។

# ប្រជាពលរដ្ឋនៅខេត្តក្រចេះកំពុងព្រួយបារម្ភពីបញ្ហាការរំលោភដីធ្លី

ប្រជាពលរដ្ឋរាប់រយគ្រួសារនៅភូមិស្រែទក់ ភូមិដូនមាស ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះកំពុង ព្រួយបារម្ភ ខណៈពេល ក្រុមហ៊ុន **ហេង សឹមឡេង** និងអាជ្ញាធរខេត្តក្រចេះរួមជាមួយស្ថាប័នពាក់ព័ន្ធដទៃទៀតបានអនុញ្ញាតឱ្យ ក្រុមហ៊ុននេះធ្វើគំរោងអភិវឌ្ឍន៍លើផ្ទៃដីចំនួន១000ហិកតា ដើម្បីអភិវឌ្ឍន៍ដំណាំកៅស៊ូ និងកសិឧស្សាហកម្ម ។

លោក **សុក មឿន** អ្នកភូមិស្រែទក់ ឃុំស្រែចារ បាននិយាយថា ប្រជាពលរដ្ឋនៅភូមិស្រែក់កំពុងព្រួយកង្វល់ស្របពេល ក្រុមហ៊ុន **ហេង ស៊ឹម ឡេង** ធ្វើការសិក្សាប៉ុន្តែមានការអនុញ្ញាតពីឃុំស្រុកខេត្ត និងស្ថាប័នពាក់ព័ន្ធឯទៀតដោយក្រុមហ៊ុននោះបានយកដីធ្លីទំហំ១000ហិកតាដើម្បីដាំកៅស៊ូ ។

នៅបន្តទៀតថា ប្រសិនបើក្រុមហ៊ុននោះយកដីធ្លី ១000 ហិកតា មែននោះវានឹងធ្វើឱ្យប៉ះពាលធ្ងន់ធ្ងរណាស់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ពីព្រោះប្រជាពលរដ្ឋមានជីវភាពក្រីក្រខ្លាំងណាស់ហើយពួកគាត់ពិតជាដាច់ពោះស្លាប់ជាមិនខាន ។

អ្នកស្រី **យ៉េន សារ៉ុន** នៅភូមិស្រែទក់បានរៀបរាប់ថា ប្រជាកសិករមានដីស្រែចំការ១ ឬ ២ហិកតាប៉ុណ្ណោះសំរាប់ប្រកបរបរចិញ្ចឹមជីវិតហើយឥឡូវនេះពួកគាត់កំពុងជ្រួលច្របល់ ដោយឮថាក្រុមហ៊ុន នឹងអភិវឌ្ឍន៍ ដាំកៅស៊ូនៅលើផ្ទៃដី ១000ហិចតា ធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគាត់ ។

ប្រជាពលរដ្ឋម្នាក់ជំនួសមុខ ឱ្យប្រជាពលរដ្ឋ២៧២គ្រួសារនៅភូមិស្រែទក់ សូមអំពាវនាវដល់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** មេត្តាជួយដល់ប្រជាពលរដ្ឋ ដោយរក្សាទុកផ្ទៃដី១000ហិកតានោះឱ្យនៅដែលពីព្រោះប្រជាពលរដ្ឋយើង អាស្រ័យលើដីទាំងនោះសំរាប់ប្រកបរបចិញ្ចឹមជីវិតកូនចៅ ។

លោក **សួន ប៊ុនធឿន** មន្ត្រីកម្មវិធីក្នុងគំរោងពង្រឹងអំណាចសហគមន៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានបញ្ជាក់ថាក្រោយពីមជ្ឈមណ្ឌលសិទ្ធិមនុស្ស បានរៀបចំវេទិកាបញ្ចេញមតិនៅឃុំស្រែចារទាក់ទងនឹងជំលោះដីធ្លីរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុនហើយមជ្ឈមណ្ឌលសិទ្ធិមនុស្សក៏បានរៀបចំរបាយការណ៍ និងលិខិតអន្តរាគមន៍ ទៅឱ្យគណៈកម្មាធិការដោះស្រាយជំលោះដីធ្លីថ្នាក់ខេត្ត និងថ្នាក់ជាតិហើយដែរប៉ុន្តែមកដល់ពេលនេះយើងមិនទាន់បានទទួលលទ្ធផលយ៉ាងណានៅឡើយទេ ។

លោក **សួន ប៊ុនធឿន** បានគូសបញ្ជាក់ថា ប្រសិនបើក្រុមហ៊ុនមិនបានបញ្ចេញលក្ខខណ្ឌច្បាប់ត្រឹមត្រូវ វានឹងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពប្រជាពលរដ្ឋ ។ ហើយកិច្ចសន្យាសម្បទានសេដ្ឋកិច្ច តំរូវឱ្យមានកិច្ចពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋហើយបើមិនបំពេញលក្ខខណ្ឌច្បាប់ត្រឹមត្រូវ វានឹងធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពប្រជាពលរដ្ឋ ហើយបើមិនបំពេញលក្ខខណ្ឌនេះទេមិនដឹងថាអភិវឌ្ឍន៍ដើម្បីអ្វី?

លោក **អ៊ី សែ** អភិបាលស្រុកស្នួលខេត្តក្រចេះបានលើកឡើងថា អាជ្ញាធរស្រុកកំពុងពិនិត្យឱ្យបានច្បាស់លាស់ចំពោះក្រុមហ៊ុនធ្វើការអភិវឌ្ឍន៍យ៉ាងម៉េចហើយប៉ះពាល់ដល់ប្រជាពលរដ្ឋប៉ុន្មានគ្រួសារ ។ លោកអភិបាលស្រុកស្នួលបានបន្តថា ដីសម្បទានសេដ្ឋកិច្ចឱ្យទៅក្រុមហ៊ុន **ហេង សឹមឡេង** ក្នុងកិច្ចសន្យារយៈពេល ៩0ឆ្នាំ ។

លោក **សួន ប៊ុនធឿន** មន្ត្រីកម្មវិធីក្នុងគំរោងពង្រឹងអំណាចសហគមន៍បានឱ្យដឹងទៀតថា ច្រើនឆ្នាំកន្លងមកហើយបញ្ហាទំនាស់ដីធ្លិមិនទាន់ដោះស្រាយ ឱ្យបានត្រឹមត្រូវតួយ៉ាងខេត្តក្រចេះ ស្ទឹងត្រែង រតនៈគីរី កោះកុង យើងអាចដោះស្រាយបញ្ហាដីធ្លីបានទាល់តែអនុវត្តទៅតាមច្បាប់ឱ្យត្រឹមត្រូវ ក្នុងនោះរដ្ឋាភិបាលគួរតែជំរុញឱ្យ មានការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវដើម្បីធ្វើឱ្យ

ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានធូរធារ និងមានលក្ខណៈល្អប្រសើរទៅថ្ងៃមុខ ។

## ការយឺតយ៉ាវបើកប្រាក់បន្ថែម៥ដុល្លារ ដល់មន្ត្រីប៉ូលីសតែប្រសើរជាងអត់

លោក **គៀត សុគន្ធ** អនុប្រធានគណបក្សសិទ្ធិមនុស្ស មានប្រសាសន៍ថា ការបន្ថែមប្រាក់៥ដុល្លារពីប្រាក់ខែមូលដ្ឋានរបស់មន្ត្រីរាជការប៉ូលីស ទាហ៊ានដែលចូលនិវត្តន៍វាជាការល្អម្យ៉ាងហើយ បើទោះជាប្រាក់នោះតិចតួច ឬយឺតយ៉ាវក៏ដោយវាគ្រាន់បើជាងអត់ ។ រដ្ឋាភិបាលមិនចាត់ការឱ្យយឺតយូរអីចឹងទេ គួរតែគិតគូរឱ្យបានឆាប់រហ័សពីព្រោះនេះជាបញ្ហាជីវភាពរស់នៅសព្វថ្ងៃម្យ៉ាងទៀតរដ្ឋាភិបាលត្រូវតែគិតគូរដលកម្មករ ដែលបាត់បង់ការងារ ធ្វើនិងចាស់ជរា ។

លោក **គៀត សុគន្ធ** បន្តថា រដ្ឋាភិបាលបែរជាចំណាយថវិកាច្រើនទៅវិញក្នុងការដំឡើងសមាជិករដ្ឋាភិបាល នេះជាការចំណាយលុយច្រើន ជាជាងគិតគូរទៅលើជីវភាពប្រជាពលរដ្ឋពោលគឺបក្សពួកក្រុមអ្នកនយោបាយប៉ុណ្ណោះ។ លោកបានបញ្ជាក់បន្ថែមថាគោលការគណបក្សសិទ្ធិមនុស្ស និងផ្តល់ប្រាក់ខែជូនមន្ត្រីរាជការ១០០ដុល្លារក្នុង១ខែ ពីព្រោះទឹកប្រាក់១០០ដុល្លារជាចំនួនសមរម្យដើម្បីទប់ទល់នឹងជីវភាពប្រចាំថ្ងៃរបស់មន្ត្រីរាជការ ។

កញ្ញា **សេង ធារី** នាយិកាមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមបានលើកឡើងថា ការដំឡើងប្រាក់៥ដុល្លារលើ ប្រាក់ខែមូលដ្ឋានរបស់មន្ត្រីរាជការប៉ូលីស ទាហ៊ាននេះវាមិនគ្រប់គ្រាន់ និងមិនសមស្របទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃនោះទេ ។ សព្វថ្ងៃទំនិញឡើងថ្លៃហើយអ្នកដែលរស់នៅទីក្រុង ជីវភាពមានការលំបាកត្រូវការចំណាយច្រើន ។

មេធាវី **សេង ធារី** ក៏បានស្តីបន្ទោសធ្ងន់ទៅលើអំពើពុករលួយ ដែលជាហេតុនាំឱ្យមន្ត្រីរាជការទទួលបានប្រាក់ខែតិចតួច។ ប្រសិនបើប្រទេសយើងមិនកើតមានអំពើពុករលួយវិញ នោះគេអាចយកប្រាក់នេះមកដំឡើងប្រាក់ខែជូនមន្ត្រីបានយ៉ាងល្អប្រសើរ ។

លោក **រ៉ុង ឈុន** ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ និងជាសកម្មជនម្នាក់ក្នុងការទាមទារដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការជាពិសេសគ្រូបង្រៀនផងនោះ ពេលនេះលោកបានប្រាប់ថាការបន្ថែមប្រាក់២ម៉ឺនរៀលគ្មានរឿងអ្វីគួរអោយចំឡែកនិងធ្វើអោយល្អប្រសើរសំរាប់ជីវភាពរស់នៅ របស់មន្ត្រីរាជការគ្រូបង្រៀនបានទេ ពីព្រោះទំនិញសព្វថ្ងៃឡើងថ្លៃលោកថា ជីវភាពរស់នៅប្រចាំសមល្មមរបស់ មន្ត្រីរាជការគ្រូបង្រៀនទាល់តែ១លានរៀលទើបមានតុល្យភាព និងតំលៃទំនិញ ។


| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| **លោក** | **ម៉ី សាន** | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| **កញ្ញា** | **គង់ វណ្ណា** | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |


**គោលនយោបាយគណបក្សសិទ្ធិមនុស្សនៅតែបន្តផ្សព្វផ្សាយជូនប្រជាពលរដ្ឋខ្មែរ!**